# របាយការណ៍ស្តីអំពីការចុះស្រាវជ្រាវ
# តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ អន្លង់វែង

**ដោយ ហ៊ុយ វណ្ណៈ**

*ថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧*

ចាប់ពីថ្ងៃទី៧ រហូតដល់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧ ក្រុមស្រាវជ្រាវចំនួន៤នាក់នៃមជ្ឈមណ្ឌលឯកសារកម្ពុជារួមមាន ស៊ីន ឃិន, ដេង ពង្សរ៉ាស៊ី, អ៊ុច សំអឿន និង ហ៊ុយ វណ្ណៈ បានចុះស្រាវជ្រាវតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ខេត្តឧត្តរមានជ័យ ជាលើកទី២ ។

## សាក្សីដែលបានសម្ភាសន៍

ក្នុងពេលបំពេញការងារនៅទីនោះ ក្រុមការងារបានជួបសាក្សីចំនួន១៤នាក់គឺ៖

សែ យុត អាយុ៥៤ឆ្នាំ ជាអនុប្រធានភូមិស្រះឈូក ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) ផ្ទះតាម៉ុក (នៅលើកូនភ្នំជិតមាត់បឹងអូរជីក)

- កាលបរិច្ឆេទៈ ៣ សីហា ២០០៧ វេលាម៉ោង ១៥:៥០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០៤
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៣០៨F
- រយៈកម្ពស់ៈ (N) ១៤° ១៤' ២៩ៈ ០៤"
- រយៈទទឹងៈ (E) ១០៤° ០៤' ៥០ៈ ៤២"

២) រោងចក្រអារឈើតាម៉ុក (នៅភូមិស្រះឈូក)

- កាលបរិច្ឆេទៈ ៣ សីហា ២០០៧ វេលាម៉ោង ១៦:០០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០៥
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៣០៩A
- រយៈកម្ពស់ៈ (N) ១៤° ១៨' ៣២ៈ ៦៣"
- រយៈទទឹងៈ (E) ១០៤° ០៤' ៤៨ៈ ៦៩"

៣) ផ្ទះខៀវសំផន (នៅជើងភ្នំដងរែក)

៤) ស្ពានតាម៉ុក (ស្ពានអូរជីក)

៥) ឃ្លាំងតាម៉ុក (ឃ្លាំងដាក់សម្ភារៈកងទ័ព និង ស្បៀងអាហារ នៅជិតជើងភ្នំដងរែក ឬ ហៅថា ឃ្លាំងតាភីន)

៦) ឃ្លាំងគ្រាប់តាម៉ុក (រកឃើញថ្មីៈ នៅជាប់ផ្លូវចូលទៅផ្ទះខៀវសំផនជិតជើងភ្នំដងរែក)

សំ ភីន អាយុ៤៨ឆ្នាំ អតីតជាប្រធានឃ្លាំងតាម៉ុក (នៅជិតជើងភ្នំដងរែក) ភូមិ ជើងភ្នំ ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) ឃ្លាំងតាម៉ុក (ឃ្លាំងដាក់សម្ភារៈកងទ័ព និង ស្បៀងអាហារ នៅជិតជើងភ្នំដងរែក ឬ ហៅថា ឃ្លាំងតាភីន)

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១៦ៈ២០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១៧
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០៩A
- រយៈកម្ពស់ៈ (N) ១៤° ២០' ០៥ៈ ៤៥"
- រយៈទទឹងៈ (E) ១០៤° ០៤' ៤៩ៈ ៩៣"

២) ផ្ទះកណ្តាលក្រោម (ផ្ទះសម្ងាត់ប៉ុលពត)

៣) ផ្ទះប៉ុលពត (នៅក្នុងបឹងអូរជីក)

៤) ទីបញ្ជាការតាម៉ុក (នៅខាងកើតទីរួមស្រុកអន្លង់វែង)

៥) ទីតាំងផលិតមីន (កន្លែងផលិតមីននៅលើភ្នំដងរែក)

៦) កន្លែងផលិតគ្រាប់កាំភ្លើងដៃ (រកឃើញថ្មីៈ នៅលើភ្នំពីររយ)

ប៉ុល សុខុម អាយុ៥១ឆ្នាំ ជាអ្នកថែរក្សាផ្ទះតាម៉ុក នៅលើកូនភ្នំជិតមាត់បឹង

ស្តីអំពី៖

១) ផ្ទះតាម៉ុក (នៅលើកូនភ្នំជិតមាត់បឹងអូរជីក)

២) ផ្ទះប៉ុលពត (នៅក្នុងបឹងអូរជីក)

ទៃ លីម (ស្រី) អាយុ៤៥ឆ្នាំ ជាក្មួយរបស់តាម៉ុក នៅភូមិស្រះឈូក ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) រោងចក្រអារឈើតាម៉ុក

២) កន្លែងដុតសព សុន សេន និងក្រុមគ្រួសារសរុបចំនួន១១នាក់ (រកឃើញថ្មីៈ នៅខាងត្បូងរោងចក្រអារឈើតាម៉ុក)

៣) ផ្ទះតាម៉ុក (រកឃើញថ្មីៈ នៅខាងលិចរោងចក្រអារឈើតាម៉ុក)

អ៊ុន យឿន អាយុ៤១ឆ្នាំ អតីតជាងឈើស្ថិតក្រោមការគ្រប់គ្រងរបស់តាម៉ុក

ស្តីអំពី៖

១) រោងចក្រអារឈើតាម៉ុក

២) ផ្ទះតាម៉ុក (រកឃើញថ្មីៈ នៅជិតរោងចក្រអារឈើតាម៉ុក)

៣) ស្ពានអូរដីក

- កាលបរិច្ឆេទៈ ៣ សីហា ២០០២ វេលាម៉ោង ១៥ៈ៤៥
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០៣
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៣០៨E
- រយៈកម្ពស់ៈ (N) ១៤° ១៤' ១២ៈ ៩៨"
- រយៈទទឹងៈ (E) ១០៤° ០៤' ៤៤ៈ ៥៦"

អ៊ុំ លីម អាយុ៣៩ឆ្នាំ អ្នកថែរក្សាប៉ុលពត

ស្តីអំពី៖

១) ផ្ទះប៉ុលពត (នៅក្នុងបឹងអូរដីក)

២) ផ្ទះកណ្តាលក្រោម (ផ្ទះសម្ងាត់ប៉ុលពត)

៣) ផ្ទះប៉ុលពត (នៅក្បាលទន្សោង)

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១១ៈ៥០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១៥
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០៤D
- រយៈកម្ពស់ៈ (N) ១៤° ២១' ១៣ៈ ៥១"
- រយៈទទឹងៈ (E) ១០៤° ០៧' ១៦ៈ ៧០"

៤) ខ្មុយលាក់ខ្លួន (នៅខាងកើតផ្ទះប៉ុលពតក្បាលទន្សោង)

៥) ការិយាល័យខៀវសំផន (នៅក្បាលទន្សោង)

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១១ៈ៤៥
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១៤
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០៤C
- រយៈកម្ពស់ៈ (N) ១៤° ២១' ១៥ៈ ៤៥"
- រយៈទទឹងៈ (E) ១០៤° ០៧' ១៦ៈ ៣៩"

៦) ផ្ទះខៀវសំផន (នៅក្បាលទន្សោង)

៧) ផ្ទះរបស់ជុំកូនខៀវសំផន (រកឃើញថ្មីៈ នៅក្បាលទន្សោង)

៨) កន្លែងកាត់ទោសប៉ុលពត

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ៩ៈ៥០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០៩
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០២C
- រយៈកម្ពស់ៈ (N) ១៤° ២០' ៣៥ៈ ៤៨"
- រយៈទទឹងៈ (E) ១០៤° ០៣' ៣៨ៈ ៦២"

៩) កន្លែងដុតសពប៉ុលពត

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ៩ៈ៣០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០៧
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០២A
- រយៈកម្ពស់ៈ (N) ១៤° ២០' ៣៣ៈ ៩១"
- រយៈទទឹងៈ (E) ១០៤° ០៣' ២៨ៈ ៣៦"

១០) ផ្ទះប៉ុលពត (នៅក្បែរកន្លែងបញ្ចុះសពប៉ុលពត)

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ៩ៈ៤០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០៨
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០២B

- រយៈកម្ពស់ (N) ១៤° ២០' ៣៣ៈ ៤៥"
- រយៈទទឹង (E) ១០៤° ០៣' ២៧ៈ ៦១"

ខាត់ សឿន អាយុ៤២ឆ្នាំ កងការពារសុនសេន នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) កន្លែងផលិតគ្រាប់កាំភ្លើងដៃ (នៅលើភ្នំពីររយ)

២) ទីតាំងផលិតមីន (នៅលើកំពូលភ្នំដងរែក)

៣) ផ្ទះសុន សេន

- កាលបរិច្ឆេទៈ ៥ សីហា ២០០២ វេលាម៉ោង ១២ៈ៤៥
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១២០
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៥០៥B
- រយៈកម្ពស់ (N) ១៤° ២០' ៤០ៈ ៨៣"
- រយៈទទឹង (E) ១០៤° ០៥' ០១ៈ ៨១"

៤) ផ្ទះតាម៉ុក (នៅភូមិផ្ទះកណ្តាល)

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១០ៈ៤០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១១
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០៣B
- រយៈកម្ពស់ (N) ១៤° ២០' ៤៦ៈ ៥៧"
- រយៈទទឹង (E) ១០៤° ០៥' ០៩ៈ ៤១"

មឿង គង់ អាយុ៣២ឆ្នាំ អ្នកបកប្រែភាសាថៃឲ្យតាម៉ុក នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) កន្លែងផលិតគ្រាប់កាំភ្លើងដៃ (នៅលើភ្នំពីររយ)

២) ទីតាំងផលិតមីន (នៅលើកំពូលភ្នំដងរែក)

ប៉ាន់ ដួ អាយុ អាយុ៤៩ឆ្នាំ នៅភូមិឃ្លាំងកណ្តាល ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) ផ្ទះតាម៉ុក (ដែលក្រោយមកក្លាយទៅជាកន្លែងក្រុមសិល្បៈរបស់តាម៉ុកៈ រកឃើញថ្មី)

ឈឹម ម៉ី អាយុ៥៥ឆ្នាំ នៅភូមិឃ្លាំងកណ្តាល ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) ផ្ទះកណ្តាលក្រោម (ផ្ទះសម្ងាត់ប៉ុលពត)

២) ផ្ទះខៀវសំផន (នៅជិតជើងភ្នំដងរែក)

៣) ផ្ទះតាម៉ុក (ដែលក្រោយមកក្លាយទៅជាកន្លែងក្រុមសិល្បៈរបស់តាម៉ុកៈ រកឃើញថ្មី)

កុយ លាភ (ស្រី) អាយុ៤៥ឆ្នាំ នៅភូមិឃ្លាំងកណ្តាល ឃុំត្រពាំងប្រិយ៍

ស្តីអំពី៖

១) ផ្ទះកណ្តាលក្រោម (ផ្ទះសម្ងាត់ប៉ុលពត)

២) ផ្ទះខៀវសំផន (នៅជិតជើងភ្នំដងរែក)

៣) ផ្ទះតាម៉ុក (ដែលក្រោយមកក្លាយទៅជាកន្លែងក្រុមសិល្បៈរបស់តាម៉ុកៈ រកឃើញថ្មី)

ហេង ខែម ហៅ ទ្រី អាយុ៥៧ឆ្នាំ ប្រធានការិយាល័យអប់រំស្រុកអន្លង់វែង

ស្តីអំពី៖

១) សាលាបឋមសិក្សាអន្លង់វែង

- កាលបរិច្ឆេទៈ ៣ សីហា ២០០២ វេលាម៉ោង ១៤ៈ៤៥
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០១
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៣០៨C
- រយៈកម្ពស់ៈ (N) ១៤° ១៣' ៤៦ៈ ៨៣"
- រយៈទទឹងៈ (E) ១០៤° ០៥' ២៧ៈ ៥៣"

២) រូបចម្លាក់ (នៅចង្កេះភ្នំដងរែក)

ម៉ក់ កេង អាយុ៤២ឆ្នាំ ជាពេទ្យជំនួយការ ស្តីអំពី៖

១) មន្ទីរពេទ្យតាម៉ុក (មណ្ឌលសុខភាពអន្លង់វែង)

- កាលបរិច្ឆេទៈ ៣ សីហា ២០០២ វេលាម៉ោង ១៥ៈ១៥
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១០២
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៣០៨D
- រយៈកម្ពស់ៈ (N) ១៤° ១៤' ០៥ៈ ១៣"

-រយៈទទឹងៈ (E) ១០៤° ០៤' ៥០ៈ ២១"

វ៉ែន លន (ស្រី) អាយុ២១ឆ្នាំ អ្នកចូលរួមស្លាប់នៅក្នុងការកាត់ទោស ប៉ុល ពត នៅឆ្នាំ១៩៩៧ នៅលើភ្នំដងរែក

ស្តីអំពីៈ

១) ដំណើរការកាត់ទោស ប៉ុល ពត

## ទីតាំងដែលរកឃើញថ្មី

ក្រុមការងារបានរកឃើញទីតាំងថ្មីចំនួន១០កន្លែង ដែលមិនទាន់បានកំណត់នៅក្នុងផែនទីដែលធ្វើដោយក្រសួងទេសចរណ៍រួមមានៈ

១) កន្លែងផលិតមីនរបស់តាម៉ុក (នៅសល់តែគ្រឹះលិចទឹក ស្ថិតនៅខាងជើងចម្ងាយ ៣០០ម៉ែត្រពីផ្ទះតាម៉ុក នៅលើកូនភ្នំជាប់មាត់បឹងអូរជីក ក្នុងភូមិអន្លង់វែង) ។

២) ផ្ទះតាម៉ុក ដែលនៅក្នុងឆ្នាំ១៩៩៧ក្លាយទៅជាផ្ទះរបស់ក្រុមសិល្បៈ ស្ថិតនៅខាងឆ្វេងដៃជាប់ផ្លូវចូលទៅផ្ទះកណ្តាលក្រោម ក្នុងភូមិឃ្សាំងកណ្តាល ឃុំត្រពាំងប្រិយ៍ ។ ផ្ទះនេះនៅសល់អាងទឹក និងសាបនៅផ្ទាល់ដី ។

៣) កន្លែងដុតសព សុន សេន និងសាច់ញាតិ ស្ថិតនៅខាងត្បូងរោងចក្រអារឈើ តាម៉ុក ចម្ងាយ១០០ម៉ែត្រ ក្នុងភូមិស្រះឈូក ឃុំត្រពាំងប្រិយ៍ ។ កន្លែងដុតសព នេះត្រូវបានពូនជាផ្នូរ និង ដាំផ្កានៅខាងលើផ្នូរនិងនៅជុំវិញផ្នូរ ។

- កាលបរិច្ឆេទៈ ៣ សីហា ២០០២ វេលាម៉ោង ១៦ៈ១០
- លេខកូដភូមិសាស្រ្តនៃទីតាំង (ID No.) ២២០១០៦
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R០៨០៣១០A
- រយៈកម្ពស់ៈ (N) ១៤° ១៨' ៣០ៈ ១៣"
- រយៈទទឹងៈ (E) ១០៤° ០៤' ៤៨ៈ ៧២"

៤) ផ្ទះតាម៉ុក ស្ថិតនៅខាងលិចរោងចក្រអារឈើតាម៉ុកចម្ងាយ១០០ម៉ែត្រ ក្នុងភូមិ ស្រះឈូក ឃុំត្រពាំងប្រិយ៍ ។ ផ្ទះនេះសង់ក្បែរដើមជ្រៃមួយដើម ហើយត្រូវបានដុតបំផ្លាញនៅឆ្នាំ១៩៩៨ មិនមានបន្សល់អ្វីសម្រាប់សម្គាល់ទេ ។

៥)	ឃ្លាំងគ្រាប់តាម៉ុក ស្ថិតនៅខាងស្តាំដៃជាប់ផ្លូវចូលទៅផ្ទះខៀវសំផន (នៅក្បែរដើងភ្នំ) នៅភូមិដើងភ្នំ ឃុំត្រពាំងប្រិយ៍ ។ នៅគ្រាដំបូង ឃ្លាំងនេះសង់អំពីឈើប្រក់ កៅស៊ូខៀវ(តង់) ។ សព្វថ្ងៃ កន្លែងនេះបានក្លាយទៅដីស្រែរបស់ប្រជាជន ។

៦)	កន្លែងផលិតគ្រាប់កាំភ្លើងដៃ(កាំភ្លើងអាកា) នៅលើភ្នំពីររយ ។ កន្លែងនេះនៅសល់ផ្ទះមួយខ្នងដែលជញ្ជាំងធ្វើអំពីឥដ្ឋស៊ីម៉ង់ត៍ គ្រឹះថ្មខាងក្រោម គ្មានដំបូល ទទឹង៦ ម៉ែត្រ បណ្តោយ៦ម៉ែត្រ និងរោងចក្រគ្រាប់កាំភ្លើងមួយខ្នងទទឹង២០ម៉ែត្រ បណ្តោយ៣០ម៉ែត្រ ។ រោងចក្រគ្រាប់នៅសល់សរសរកម្ពស់៤ម៉ែត្រ មុខកាត់ ០,២៥ម៉ែត្រចំនួន២១ដើម និងគ្រឹះថ្មខាងក្រោម ។

- កាលបរិច្ឆេទៈ ៥ សីហា ២០០២ វេលាម៉ោង ១០ៈ៣០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១៨
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៥០៣A
- រយៈកម្ពស់ៈ (N) ១៤° ១៩' ៥៤ៈ ៥០"
- រយៈទទឹងៈ (E) ១០៤° ០៣' ២៤ៈ ២៥"

៧)	ឃ្លាំងតាម៉ុក ស្ថិតនៅកែងផ្លូវចូលទៅផ្ទះកណ្តាល នៅក្នុងភូមិផ្ទះកណ្តាល ឃុំត្រពាំង ប្រិយ៍ ។ ឃ្លាំងនេះនៅសល់គ្រឹះថ្ម និងសាបផ្ទាល់ដី ។

៨)	ផ្ទះតាម៉ុក ស្ថិតនៅខាងត្បូងផ្ទះកណ្តាលចម្ងាយ៥០ម៉ែត្រ នៅក្នុងភូមិកណ្តាល ឃុំប្រពាំងប្រិយ៍ ។ ផ្ទះនេះសង់អំពីថ្ម និងប្រក់ក្បឿងឈើធ្វើអំពីដើមសំរោង ដែលមានទទឹង៦ម៉ែត្រ និង បណ្តោយ៨ម៉ែត្រ ។ ផ្ទះនេះបានរក្សារូបរាងនៅដដែល ។ តាម៉ុកបានយកផ្ទះនេះសម្រាប់ជាកន្លែងបញ្ជាការកងទ័ពមួងម្កាល ។ បច្ចុប្បន្ន ផ្ទះនេះបានក្លាយទៅជាទីបញ្ជាការបណ្តោះអាសន្នរបស់"CMAC"

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១១ៈ០០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១២
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០៤A
- រយៈកម្ពស់ៈ (N) ១៤° ២០' ៤២ៈ ១៦"
- រយៈទទឹងៈ (E) ១០៤° ០៥' ០៩ៈ ៩៧"

៩)　ឃុំាំងគ្រាប់ប៉ុលពត　(នៅទល់មុខកន្លែងកាត់ទោសប៉ុលពត ។　ឃ្លាំងនេះនៅរក្សាទ្រង់ទ្រាយនៅឡើយ ដែលធ្វើអំពីថ្មនៅខាងក្រោម និងឈើខាងលើ ប្រក់ស័ង្កសី)

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១០ៈ៣០
- លេខកូដភូមិសាស្រ្តនៃទីតាំង (ID No.) ២២០១១០
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០៣A
- រយៈកម្ពស់ៈ (N) ១៤° ២០' ៣១ៈ ៦៨"
- រយៈទទឹងៈ (E) ១០៤° ០៣' ៣៩ៈ ២៧"

១០)　ផ្ទះរបស់ ដុំ (កូនរបស់ខៀវសំផន) នៅក្បាលទន្សោង ខាងកើតការិយាល័យរបស់ ខៀវសំផន ចម្ងាយ៤០០ម៉ែត្រ ។ ផ្ទះនោះនៅសល់តែគ្រោងសសរ និង ដំបូល ដែលមានទទឹង៦ម៉ែត្រ បណ្តោយ៨ម៉ែត្រ ។

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១១ៈ៤០
- លេខកូដភូមិសាស្រ្តនៃទីតាំង (ID No.) ២២០១១៣
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R០៨០៤០៤ B
- រយៈកម្ពស់ៈ (N) ១៤° ២១' ២០ៈ ០៧"
- រយៈទទឹងៈ (E) ១០៤° ០៧' ១១ៈ ៣៦"

## ទីតាំងដែលមិនទាន់បានដាក់ផ្លាកសញ្ញា

ទីតាំងមាននៅលើដែនទី ដែលក្រសួងទេសចរណ៍មិនទាន់បានដាក់ផ្លាកសញ្ញារួមមានៈ

១) ទីបញ្ជាការតាម៉ុក (ស្ថិតនៅប៉ែកខាងកើតទីរួមស្រុកអន្លង់វែងចម្ងាយ១៥០ម៉ែត្រ)

- កាលបរិច្ឆេទៈ ៧ សីហា ២០០២ វេលាម៉ោង ១១ៈ០០
- លេខកូដភូមិសាស្រ្តនៃទីតាំង (ID No.) ២២០១២១
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៧០៤A
- រយៈកម្ពស់ៈ (N) ១៤° ១៣' ៥៤ៈ ៥៧"
- រយៈទទឹងៈ (E) ១០៤° ០៥' ០០ៈ ៦៦"

២) មន្ទីរពេទ្យតាម៉ុក

៣) ស្ពានតាម៉ុក

៤) រូបចម្លាក់

៥) ផ្ទះនួនជា

៦) មន្ទីរពេទ្យនៅភូមិផ្ទះកណ្តាល

៧) ផ្ទះសំណាក់

- កាលបរិច្ឆេទៈ ៤ សីហា ២០០២ វេលាម៉ោង ១២ៈ៣០
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១៦
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៤០៥B
- រយៈកម្ពស់ៈ (N) ១៤° ២០' ៥១ៈ ៧០"
- រយៈទទឹងៈ (E) ១០៤° ០៥' ០៨ៈ ០៥"

៨) សាលានយោបាយ

- កាលបរិច្ឆេទៈ ៥ សីហា ២០០២ វេលាម៉ោង ១២ៈ២៥
- លេខកូដភូមិសាស្ត្រនៃទីតាំង (ID No.) ២២០១១៩
- លេខឯកសារក្នុងម៉ាស៊ីនGPS(File#) R ០៨០៥០៥A
- រយៈកម្ពស់ៈ (N) ១៤° ២១' ០០ៈ ២៩"
- រយៈទទឹងៈ (E) ១០៥° ០៥' ២៩ៈ ៨០"

៩) សាលាប្រជុំនយោបាយ

## ទីតាំងដែលបានដាក់ផ្លាកសញ្ញាខុស

ទីតាំងមាននៅលើដែនទី ដែលក្រសួងទេសចរណ៍បានដាក់ផ្លាកសញ្ញាខុសទីតាំងរួមមានៈ

១) ផ្ទះខៀវសំផន នៅជើងភ្នំ ។ ផ្លាកសញ្ញានេះត្រូវប្តូរទីតាំង ដោយយកទៅដាក់នៅខាងជើងកន្លែងចាស់ចម្ងាយ២០០ម៉ែត្រ ឬចំខាងមុខផ្ទះយាយញ៉ៅ នៅភូមិជើងភ្នំ ឃុំត្រពាំង ប្រិយ៍ ពីព្រោះផ្លូវនេះចូលទៅចំផ្ទះរបស់ ខៀវ សំផន តែម្តង ។

២) ផ្ទះខៀវសំផន នៅក្បាលទន្សោង ។ ផ្លាកសញ្ញានេះបានដាក់នៅចំខាងមុខផ្ទះរបស់ ជុំ ដែលជាកូនរបស់ខៀវសំផន ។ ដូច្នេះត្រូវយកមកដាក់នៅក្បែរការិយាល័យរបស់ខៀវសំផន វិញ ដែលផ្លាកសញ្ញានេះត្រូវប្តូរពីទីតាំងចាស់មកខាងមុខចម្ងា៣០០ម៉ែត្រ ។

## ទីតាំងដែលនៅមានមន្ទិលសង្ស័យ

ទីតាំងមាននៅលើផែនទីរបស់ក្រសួងទេសចរណ៍ ប៉ុន្តែក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅមានមន្ទិលសង្ស័យរួមមាន៖

១) ផ្ទះនួនជាៈ តាមរយៈផែនទីរបស់ក្រសួងទេសចរណ៍ ក្រុមការងារមិនបានរកឃើញផ្លាកសញ្ញាសំគាល់ផ្ទះនួន ជា ហើយក៏មិនបានរកឃើញគ្រឹះសំណង់សេសសល់នៅទីនោះដែរ ។

២) សាលាប្រជុំនយោបាយ ៈ តាមរយៈផែនទីរបស់ក្រសួងទេសចរណ៍ ក្រុមការងារមិនបានរកឃើញផ្លាកសញ្ញាសំគាល់នៃ សាលាប្រជុំនយោបាយ ហើយក៏មិនបានរកឃើញគ្រឹះសំណង់សេសសល់នៅទីនោះដែរ ។

## ទីតាំងមួយដែលបានប្រើឈ្មោះពីរ

ទីតាំងតែមួយដែលមាននៅលើផែនទីរបស់ក្រសួងទេសចរណ៍ ហើយបានកំណត់ឈ្មោះទីតាំង ខុសគ្នាគឺ៖ ផ្ទះកណ្តាលក្រោម ។ នៅលើផែនទីបានដៅចំណុច និង កំណត់យកឈ្មោះទីតាំងនេះថា "ផ្ទះកណ្តាលក្រោម" ក៏ប៉ុន្តែនៅលើផ្លាកសញ្ញាសំគាល់ទីតាំងបានសរសេរថា "ផ្ទះសម្ងាត់ប៉ុលពត" ។

## ទីតាំងដែលបានកំណត់ចំណុចខុសនៅលើផែនទីរបស់ក្រសួងទេសចរណ៍

ក្រុមការងារបានពិនិត្យឃើញថា នៅលើផែនទីរបស់ក្រសួងទេសចរណ៍បានកំណត់ចំណុចទីតាំងខុសចំនួនពីរកន្លែងគឺ ១) ទីបញ្ជាការតាម៉ុក និង២) សាលាបឋមសិក្សាអន្លង់វែង ។ ទីតាំងទាំងពីរនេះត្រូវកំណត់នៅលើផែនទីឲ្យស្របនឹងផ្លូវ(ស្ថិតនៅខាងត្បូងផ្លូវ) ឆ្ពោះទៅកាន់ខេត្តព្រះវិហារ ។

## យោបល់បន្ថែម៖

តាម៉ុក បានគ្រប់គ្រងតំបន់អន្លង់វែងនៅផ្នែកខាងលើភ្នំដងរែកចាប់ពីឆ្នាំ១៩៨២ ហើយនៅ ឆ្នាំ១៩៨៩ បន្ទាប់ពីកងទ័ពវៀតណាមធ្វើមាតុភូមិនិវត្តន៍ពីប្រទេសកម្ពុជា តាម៉ុក បានវាយដណ្តើម

យកផ្នែកខាងក្រោមភ្នំដងរែកនិងទីរួមស្រុកអន្លង់វែង ។ ចាប់ពីឆ្នាំ១៩៩០មក តាម៉ុក បានកសាងសំណង់ធំៗជាច្រើន ទាំងនៅលើភ្នំនិងនៅទីរួមស្រុកអន្លង់វែង ។ នៅឆ្នាំ១៩៩៨ តាម៉ុក បានបោះបង់ចោលតំបន់អន្លង់វែង បន្ទាប់ពីកម្លាំងដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់(តាម៉ុក) ស្ទើរជិត ពាក់កណ្តាល បានផ្តាច់ខ្លួននិងធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

ដើម្បីទទួលបានពត៌មានច្រើននិងច្បាស់លាស់ស្តីអំពីទីតាំងនីមួយៗ សម្រាប់បញ្ចូលទៅក្នុងសៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍ ក្រសួងទេសចរណ៍គួរតែជួបសម្ភាសន៍ជាមួយ អតីតមេដឹកនាំខ្មែរក្រហមនៅអន្លង់វែងមួយចំនួនដូចជា នួន ទៅ អតីតជំនួយការតាម៉ុកទទួលបន្ទុកភស្តុភា សព្វថ្ងៃរស់នៅផ្សារដើមក្រឡាញ់ ខេត្តសៀមរាប និងមនុស្សមួយចំនួនទៀតដូចជា ង៉ុន , ខៀវ សំផន និង នួន ជា ៕